ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

~~~~~~~~~~~~~~~~~~~~~~

ក្រសួងសុខាភិបាល

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

# របាយការណ៍

## កិច្ចប្រជុំបណ្តាញក្រុមថែទាំអ្នកជំងឺអេដស៍តាមផ្ទះ និងតាមសហគមន៍ ប្រចាំតំបន់ ខេត្តបាត់ដំបង

**Battambang Regional Network Meeting for Home and Community Based Care for HIV/AIDS**

បាត់ដំបង, ថ្ងៃទី ០៤-០៦ ខែ មករា ឆ្នាំ ២០១០

រៀបចំដោយ

ឧបត្ថម្ភដោយ
~~~~~~~~~~~~~~~~~~~~~~

# របាយការណ៍កិច្ចប្រជុំបណ្តាញអ្នកថែទាំអ្នកជំងឺអេដស៍
# តាមផ្ទះ និងសហគមន៍ប្រចាំតំបន់ខេត្ត បាត់ដំបង

**១_ កាលបរិច្ឆេទ** : ពីថ្ងៃទី ០៤ - ០៦ ខែ មករា ឆ្នាំ ២០១០

**២_ ទីកន្លែង** : សាលប្រជុំមន្ទីរសុខាភិបាលខេត្ត បាត់ដំបង

**៣_ ឧបត្ថម្ភដោយ** : មូលនិធិការពារជំងឺឆ្លង នៃសហរដ្ឋអាមេរិក US CDC

**៤_ រៀបចំដោយ** : រៀបចំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ

**៥_ គោលបំណងនៃសិក្ខាសាលា** :

- ពិនិត្យ-ពិភាក្សា លើការអនុវត្តន៍អំពីទំរង់របាយការណ៍របស់ក្រុមថែទាំអ្នកជំងឺអេដស៍តាមផ្ទះ ។
- ពិនិត្យ-វាយតំលៃសកម្មភាពការងារថែទាំជំងឺអេដស៍តាមផ្ទះកន្លងមក ។
- ផ្លាស់ប្តូរបទពិសោធន៏ក្នុងរវាងបណ្តាញថែទាំអ្នកផ្ទុកមេរោគអេដស៍តាមផ្ទះនៃខេត្ត US CDC ។

**៦_ សមាសភាពចូលរួម:** មានចំនួន ៦២ នាក់ដែលសិក្ខាកាមចូលរួមមកពី ៤ខេត្ត និង អង្គការក្រៅរដ្ឋាភិបាល ចូលរួមមាន US-CDC, KHANA, FHI, AHEAD, BFD, PC , BWAP, CSCN, USAID, KYA , SEADO, ) និង មន្ត្រីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ។ ក្នុងខេត្តនិមួយៗមានប្រធានកម្មវិធីអេដស៍ខេត្ត មន្ត្រីទទួលបន្ទុក CoC coordinator , មន្ត្រីទទួល បន្ទុក HIV/AIDS នៅតាមស្រុកប្រតិបត្តិមានសេវាថែទាំ និង ព្យាបាលបន្ត ។

- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ កាមរោគ និងសើស្បែក ចំនួន ២១ រូប
- ខេត្ត បាត់ដំបង ចំនួន ៣០ រូប ( មន្ត្រីរដ្ឋាភិបាលចំនួន ១២ រូប និង អង្គការក្រៅរដ្ឋាភិបាល ១៨ រូប)
- ខេត្ត ពោធិសាត់ ចំនួន ៦ រូប ( មន្ត្រីរដ្ឋាភិបាលចំនួន ០៤ រូប និង អង្គការក្រៅរដ្ឋាភិបាល ០២ រូប)
- ខេត្ត បន្ទាយមានជ័យ ចំនួន ១១ រូប ( មន្ត្រីរដ្ឋាភិបាលចំនួន ៦ រូប និង អង្គការក្រៅរដ្ឋាភិបាល ០៥ រូប)
- ខេត្ត ប៉ៃលិន ចំនួន ០៩ រូប ( មន្ត្រីរដ្ឋាភិបាលចំនួន ០៤ រូប និង អង្គការក្រៅរដ្ឋាភិបាល ០៥ រូប)

**៧_ សកម្មភាព:**

**ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១០**

**ពេលព្រឹក:**

កិច្ចប្រជុំបណ្តាញក្រុមថែទាំអ្នកជំងឺអេដស៍តាមផ្ទះ ធ្វើឡើងដោយវេជ្ជបណ្ឌិត **លី ពេញស៊ុន** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និង កាមរោគ ។

- កិច្ចស្វាគមន៍របស់លោកវេជ្ជ. **គុយ សុខ** អនុប្រធានមន្ទីរសុខាភិបាលខេត្ត បាត់ដំបង ។

- មតិចូលរួមនិងចំណាប់អារម្មណ៍របស់លោកវេជ្ជ. **លី ទាំងធី** តំណាងអង្គការ US-CDC

- មតិសំណេះសំណាល និងការប្រកាសបើកកិច្ចប្រជុំបណ្តាញថែទាំអ្នកជំងឺអេដស៍តាមផ្ទះ និងក្នុងសហគមន៍ ប្រចាំតំបន់ខេត្តបាត់ដំបងដោយវេជ្ជបណ្ឌិត **លី ពេញស៊ុន** ។ លោកបានសម្តែងការកោតសរសើរចំពោះកិច្ចខំប្រឹងប្រែងរបស់ក្រុមថែទាំតាមផ្ទះ និង សហគមន៍ដែលបានអនុវត្តន៍ ១១ឆ្នាំ កន្លងមកក្នុងការថែទាំអ្នកជំងឺអេដស៍ ដោយបានរួមចំណែកការកាត់បន្ថយអត្រាឈឺនិងស្លាប់បានច្រើន។

- ការបង្ហាញពីការណែនាំអោយគ្នាដោយលោកវេជ្ជ. **ឱុច សារុន** មន្រ្តីផ្នែកថែទាំជំងឺអេដស៍
- ការបង្ហាញពីគោលបំណងណែនាំការងារថែទាំអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍តាមផ្ទះនិងតាមសហគមន៍ ដោយលោកវេជ្ជ. **ស៊ឹម សូផៃ** ដោយមានការពិភាក្សាគ្នាយ៉ាងផុលផុស នឹងធ្វើការកែតំរូវ មួយចំនួនពីតួនាទីភារៈកិច្ចរបស់ក្រុម ថែទាំអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍តាមផ្ទះ និងតាមសហគមន៍ ។
- ការថែទាំព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយលោកវេជ្ជ. **សេខ ឧុធី** អនុប្រធានផ្នែកថែទាំជំងឺអេដស៍នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ ។
- ការបង្ហាញពីសកម្មភាពឆ្លើយតបរួមគ្នាដោយលោកវេជ្ជ. **សារិត សុវណ្ណរិទ្ធ** អនុប្រធានផ្នែកថែទាំ ជំងឺអេដស៍នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ។

**<u>ពេលរសៀល:</u>**

- ការបង្ហាញពីរបាយការណ៍សកម្មភាពសេវាថែទាំអ្នកផ្ទុកមេរោគអេដស៍អ្នកជំងឺអេដស៍តាមផ្ទះត្រីមាសទី៣ ២០០៩ ដោយ លោកវេជ្ជ. **ឱុច សារុន** មន្រ្តីផ្នែកថែទាំជំងឺអេដស៍ នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ការបង្ហាញពីរបាយការណ៍សកម្មភាពសេវាថែទាំអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍តាមផ្ទះរបស់ ខេត្តបាត់ដំបង ដោយ លោកវេជ្ជ. **ស៊ូ សានិត** ប្រធានកម្មវិធីកម្មវិធីអេដស៍មន្ទីរសុខាភិបាល បាត់ដំបង។
- ការបង្ហាញពីសមិទ្ធផល និង បទពិសោធន៍ ការផ្តល់សេវា ថែទាំអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ តាមផ្ទះ និងសហគមន៍ ដោយតំណាងអង្គការ AHEAD ប្រចាំខេត្តបាត់ដំបង-បន្ទាយមានជ័យ និង ប៉ៃលិន ។
- ការបង្ហាញពីបទពិសោធន៍ ការផ្តល់សេវា ថែទាំអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ តាមផ្ទះ និងសហគមន៍ ដោយលោកមន្រ្តីអង្គការ CSCN ប្រចាំខេត្តពោធិសាត់ ។
- ការបង្ហាញពីបទពិសោធន៍ ការផ្តល់សេវា ថែទាំអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ តាមផ្ទះ និងសហគមន៍ ដោយលោកមន្រ្តីអង្គការធម្មយាត្រា Bantey Mean Chey ។

**ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១០**

**ពេលព្រឹក:**

- ការបង្ហាញពីទំរង់របាយការណ៍សកម្មភាពសេវាថែទាំអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍តាមផ្ទះ និងតាមសហគមន៍ត្រីមាសទី ៣ ឆ្នាំ ២០០៩ ធៀបនឹងរបាយការណ៍ត្រីមាសទី ២ ឆ្នាំ ២០០៩ ដោយ លោក. **ម៉ូ សំអាត** មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ ដោយមានសំណួរ-ចំឡើយ និងមានការពិភាក្សា ។
- ការបង្ហាញពីគោលការណ៍ណែនាំសំរាប់បំពេញលើទំរង់របាយការណ៍ថែទាំអ្នកផ្ទុកមេរោគអេដស៍ អ្នកជំងឺអេដស៍តាមផ្ទះដោយ លោក. **ម៉ូ សំអាត** មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យនិង លោកវេជ្ជ **ស៊ិត សុវណ្ណរិទ្ធ** រួមមាន មានសំណួរ-ចំឡើយនិង ចំលើយ ។

-

**ពេលរសៀល:**

- ការបង្ហាញពីរបៀបប្រើប្រាស់បញ្ជីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍តាមផ្ទះ ដោយលោកវេជ្ជ. **សេង ឌុធី** មាន សំណួរ-ចំឡើយ និងការពិភាក្សា។
- ការបង្ហាញពីគោលការណ៍នែនាំនៃការប្រើប្រាស់ទំរង់បញ្ជីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ ដោយលោក. **លាង សុផាន់ណា** និងលោក. **ម៉ូ សំអាត** ដោយមានសំណួរ-ចំឡើយ និងមានការពិភាក្សាលំអិត ។

**ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០**

**ពេលព្រឹក:**

ការអនុវត្តពីការបំពេញនៃការប្រើប្រាស់ទំរង់របាយការណ៍សកម្មភាពសេវាថែទាំអ្នកផ្ទុកមេរោគអេដស៍អ្នកជំងឺអេដស៍តាមផ្ទះដោយ លោក. **លាង សុផាន់ណា** និងលោក .**ម៉ូ សំអាត** ដោយមាន សំណួរ-ចំឡើយ និងមានការពិភាក្សាក្រុមតូចលំអិតពីបញ្ហា និងដំណោះស្រាយដែលទាក់ទងនឹងការផ្តល់សេវាថែទាំអ្នកផ្ទុកមេរោគអេដស៍អ្នកជំងឺ អេដស៍តាមផ្ទះ យ៉ាងផុលផុស។

**ពេលរសៀល:**

- ការពិភាក្សាទូទៅ
- វាយតំលៃវគ្គកិច្ចប្រជុំ
- លោកវេជ្ជ.**មាស ឌុណ្ណី** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ បានធ្វើការធ្វើដំណោះស្រាយរាល់បញ្ហាមួយចំនួនដែលលើកឡើងតាមបណ្តាខេត្ត និង អង្គការ ពាក់ពន្ធ័នានា ។

## ៨~ លទ្ធផល:

### ៨.១. ចំណុចល្អ:

- មន្ទីរសុខាភិបាលខេត្ត ផ្តល់ទីកន្លែងសំរាប់ដំណើរការកិច្ចប្រជុំ
- មានគំរូរបាយការណ៏មួយដែលមានលក្ខណ: ស្តង់ដា
- សិក្ខាកាមយល់ដឹងពីការបំពេញទំរង់របាយការណ៏ Home Base Care
- បានធ្វើការពិភាក្សាយ៉ាងផុលផុស

### ៨.២. បញ្ហា និង ដំណោះស្រាយ :

- អ្នកជំងឺបានធ្វើការផ្លាស់ប្តូរទីកន្លែង ( ថៃ —កម្ពុជា)
- អ្នកជំងឺមានសុខភាពល្អទៅធ្វើការនៅឆ្ងាយ នាំអោយក្រុមការងារចុះទៅមិនបានជួបគាត់ /ព្យាយាមចុះទៅដល់ផ្ទះរបស់ពួកគាត់ ( AHEAD )
- អ្នកផ្ទុកមេរោគអេដស៏ខ្លះនៅតែបន្តលាក់មុខ ( CSCN )
- ថវិកាបញ្ជូននៅមានកំរិត /ផ្តល់លទ្ធភាពចំពោះអ្នកដែលក្រីក្របំផុតមានសិទ្ធជាអាទិភាព ( PC )
- អ្នកជំងឺចល័ត ( បន្ទាយមានជ័យ ប៉ៃលិន)
- របាយការណ៏ពីក្រុម-សហគមន៍យឺតយ៉ាវ និង មិនទាន់បានត្រឹមត្រូវល្អ
- មណ្ឌលសុខភាពរាំងទិលនៃស្រុកកណ្ឌៀង ឆ្លងបឹង/ទន្លេ ពិបាកក្នុងការជួបអ្នកជំងឺ/លុះត្រាធ្វើការណាត់ជាមុន
- ថវិកាធ្លាក់មិនទៀងទាត់ ( KHANA partners )
- ខ្វះការទំនាក់ទំនងពីផ្នែកសេវានិមួយៗក្នុងការគ្រប់គ្រងថែទាំ និងបញ្ជូន (BMC for site not get LR yet)
- មិនទាន់មានអ្នកគ្រប់គ្រង Data management (BMC )
- NGOs មួយចំនួនផ្លាស់ប្តូរមន្ត្រីគ្រប់គ្រងញឹកញាប់ពេក/នាំអោយមានដាច់ថវិការ
- អ្នកជំងឺមកទទួលសេវា OIs/ART មិនទៀងទាត់តាមការណាត់
- អ្នកជំងឺមានកូនដោយថៃដន្យ NCHADS បាន Developed SOP for Positive prevention is nearly final soon through on Sub-working Group of HBC

## ៩~ សំណូមពរ

- សូមអោយអង្គការ/កម្មវិធីជាតិ ប្រើប្រាស់គំរូរបាយការណ៏តែមួយ
- សូមកុំប្តូរទំរង់របាយការណ៏ញឹកញាប់ពេក
- សូមពង្រីកការចុះទៅតាមសហគមន៍
- បន្ថែមថវិកាសំរាប់ប្រជុំ អភិបាលតាមដានតាមសកម្មភាពរបស់ក្រុមថែទាំ
- សុំថវិកាប្រជុំ MMM
- ពិនិត្យស្ថានភាពអ្នកជំងឺអេដស៏ និងផ្ទេរអ្នកជំងឺពីស្រុកប្រតិបត្តិដែលនៅជាប់ព្រុំដែនខ្មែរ ថៃ ។

- សុំ NCHADS ពិនិត្យ និង កែសំរួលលើសមាជិកអនុក្រុម Sub Working Group HBC ឡើងវិញ។
- សុំអោយ NCHADS លើកទឹកចិត្តអ្នកផ្តល់សេវា តាមរយៈកិច្ចប្រជុំ/សិក្ខាសាលា ឬ ប្រាក់លើកទឹកចិត្ត ។
- សុំអោយ NCHADS ពិនិត្យនិងជំរុញវរកយុទ្ធសាស្រ្តល្អៗដូចជា Positive prevention ដើម្បីចូលរួមចំណែកក្នុងការអោយអ្នកផ្ទុកមេរោគអេដស៍មានការផ្លាស់ប្តូរការប្រព្រឹត្តិ ។

កិច្ចប្រជុំបានបញ្ចប់នូវល្ងាចថ្ងៃទី៦ខែមករាឆ្នាំ២០១០ វេលាម៉ោង១៦:៣០ នាទី ដោយលោកវេជ្ជ. **មាស ទុឡឺ** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ មានមតិសំណេះសំណាលផ្តាំផ្ញើរនិងប្រកាសបិទកម្មវិធី ។

ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០

អ្នកធ្វើរបាយការណ៏

វេជ្ជ. **សេខ ខុធី**

បានឃើញ និង ឯកភាព

ប្រធានមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹង

ជំងឺអេដស៍សើស្បែក និង កាមរោគ

វេជ្ជ. មាន ឈីវុន